ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ចិញ្ចឹមក្តាមថ្មនៅក្នុងស្រះ




រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម** (ARDB)


ខែឧសភា ឆ្នាំ២០២៥

# មាតិកា


**១-សេចក្តីផ្តើម** .................................................. 1

**២-លក្ខណៈជីវសាស្រ្តរបស់ក្តាមថ្ម** .................................................. 1

**៣-បច្ចេកទេសចិញ្ចឹមក្តាមថ្មក្នុងស្រះ** .................................................. 2

៣.១. ការរៀបចំស្រះចិញ្ចឹមក្តាមថ្ម .................................................. 2

៣.២. ការដាក់កូនក្តាមថ្មពូជ .................................................. 2

៣.៣. ចំណី និងការផ្តល់ចំណី .................................................. 3

៣.៤. ការគ្រប់គ្រង និងថែទាំ .................................................. 4

៣.៥. ការបង្ការជំងឺ .................................................. 4

៣.៦. ការប្រមូលផល .................................................. 5

**៤-គម្រោងអាជីវកម្មចិញ្ចឹមក្តាមថ្ម** .................................................. 6

៤-១- គម្រោងចិញ្ចឹម .................................................. 6

៤-២- ការវិភាគសេដ្ឋកិច្ចការចិញ្ចឹមក្នុង១វគ្គ .................................................. 6

៤-៣- ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់ .................................................. 7

៤-៤- ការវិភាគលើខ្សែច្រវាក់តម្លៃ .................................................. 8

**៥-ហានិភ័យ-បញ្ហាប្រឈម** .................................................. 8

**៦-សេចក្តីសន្និដ្ឋាន** .................................................. 9

**ប្រភពឯកសារសម្រាប់សិក្សាស្រាវជ្រាវ** .................................................. 10

## ១-សេចក្ដីផ្ដើម

ក្ដាមថ្មគឺជាប្រភេទសត្វទឹកប្រៃដែលមិនសូវលំបាកក្នុងការចិញ្ចឹមថែទាំ ដោយចំណាយទុនតិចហើយអាចឆាប់ទទួលផល បើសិនជាកសិករមានទីតាំង និងលក្ខខណ្ឌសមស្របក្នុងការប្រកបអាជីវកម្មមួយនេះ។ ប្រជាកសិករដែលរស់នៅតំបន់ទឹកភ្លាវ និងទឹកប្រៃអាចប្រកបអាជីវកម្មចិញ្ចឹមបាន ពីព្រោះផលិផលក្ដាមថ្មមានតម្រូវការក្នុងទីផ្សារ និងតម្លៃសេដ្ឋកិច្ចខ្ពស់។ ការចិញ្ចឹមក្ដាមថ្មអាចមានច្រើនរបៀប ដូចជាការចិញ្ចឹមក្នុងស្រះ ក្នុងអាងស៊ីម៉ង់ត៍ ឬការចិញ្ចឹមដាក់ក្នុងប្រអប់ ដោយផ្ដល់ចំណីចម្រុះ (ប្រភេទចំណីក្រៀម និងស្រស់)មានដូចជា÷ កូនត្រីល្អិត ខ្យង កូនបង្គារ ក្ដាម។ល។ ការចិញ្ចឹមក្ដាមថ្មរបស់កសិករកម្ពុជាភាគច្រើនមានលក្ខណៈជាការចិញ្ចឹមបែបបំប៉នកូនក្ដាម ដែលអ្នកនេសាទអាចចាប់បានពីធម្មជាតិនៅចន្លោះខែឧសភាដល់ខែកញ្ញា ជារៀងរាល់ឆ្នាំ។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះចំនួនអ្នកចិញ្ចឹមមានការកើនឡើង បានបង្កផលលំបាកដល់ការទិញកូនក្ដាមពូជពីអ្នកនេសាទ។ ក្រៅពីនេះ ការប្រែប្រួលអាកាសធាតុ និងជំនោរទឹកសមុទ្រក៏ធ្វើឱ្យប៉ះពាល់ដល់ដំណើរការចិញ្ចឹមក្ដាមថ្មផងដែរ។

## ២-លក្ខណៈជីវសាស្ត្ររបស់ក្ដាមថ្ម ÷

ក្ដាមថ្មគឺជាប្រភេទសត្វទឹកប្រៃរស់នៅក្នុងដីល្បាប់ភក់តាមព្រៃកោងកាងនៃតំបន់ឆ្នេរនិងដែសមុទ្រ។ ក្ដាមថ្មមានរាងកាយសំប៉ែតគ្របដណ្ដប់ដោយសំបក និងស្នូកដ៏រឹងមាំ នៅតាមគែមខ្នងខាងមុខនៃស្នូកមានបន្លាចំនួនប្រាំមួយនៅចន្លោះភ្នែកទាំងពីរ និងបន្លាស្រួចចំនួនប្រាំបួននៅអមសងខាង មានដង្កៀបមួយគូជើងដើរបីគូ រួមនឹងជើងទីបួនមួយគូដែលមានចុងរាងសំប៉ែតប្រើសម្រាប់ហែលទឹក ឬហៅថាជើងហែលទឹក។ ចំពោះក្ដាមឈ្មោល ជើងគូទីបួននេះប្រើដើម្បីចាប់ក្ដាមញីកំឡុងពេលបន្តពូជ ចំណែកក្ដាមញីប្រើសម្រាប់កោសពងមុនពេលញាស់។




ដំណាក់កាលដំបូង ក្ដាមថ្មមានចរិតស៊ីចំណីប្រភេទសត្វ និងរុក្ខជាតិប្លង់តុង នៅពេលក្ដាមពេញវ័យវាស៊ីប្រភេទកូនត្រី បង្កង បង្គា ខ្យង សត្វល្អិតតូចៗ សារ៉ាយ ស្លែរ និងប្រភេទរុក្ខជាតិទឹកមួយចំនួន។ ក្ដាមថ្មត្រូវការសកដើម្បីលូតលាស់ និងធំធាត់ឡើងចន្លោះពី ២០-៥០%នៃទំហំដងខ្លួនក្នុងការសកម្ដងៗ។ ក្រោយពេលសក ស្នូក ដងខ្លួនក្ដាមទាំងមូលរួមទាំងជើង និងដង្កៀបផងមានសភាពទន់ ជ្រាយ ដែលងាយនឹងរងគ្រោះថ្នាក់ដោយប្រភេទសត្វផ្សេង ឬក្ដាមថ្មផ្សេងទៀតដែលនៅក្នុងស្រះចាប់ធ្វើជាចំណី។

អាយុកាលជាមធ្យមរបស់ក្តាមថ្មចន្លោះពី ២-៤ឆ្នាំ មានទំហំខ្លួនចន្លោះពី ១៩-២៨សង់ទីម៉ែត្រ និងទម្ងន់ពី ១-៣គីឡូក្រាមក្នុង១ក្បាល ដោយជាទូទៅគេសង្កេតឃើញក្តាមថ្មឈ្មោលធ្ងន់ជាងក្តាមថ្មញី។

**៣-បច្ចេកទេសចិញ្ចឹមក្តាមថ្ម ÷**

បច្ចេកទេសសំខាន់ៗនៃការចិញ្ចឹមក្តាមថ្មតាមបែបពាក់កណ្តាលប្រពលវប្បកម្មដែលជាចំណេះដឹងបន្ថែមដល់ប្រជាកសិករកម្ពុជា រួមមានដូចខាងក្រោម÷

**៣.១. ការរៀបចំស្រះចិញ្ចឹមក្តាមថ្ម÷**

ស្រះចិញ្ចឹមក្តាមថ្ម ត្រូវជ្រើសរើសទីតាំងនៅក្បែរប្រភពទឹក ងាយស្រួលក្នុងការបញ្ចេញបញ្ចូលទឹក ជាតំបន់ដែលគ្មានសារធាតុពុល ថ្នាំសម្លាប់សត្វល្អិត ការបំពុលសរីរាង្គ និងថ្នាំគីមី។ ស្រះគួរមានទំហំធំទូលាយចាប់ពី ៥ ០០០ម៉ែ$^{២}$ ជម្រៅចន្លោះពី ១-១.៨ម៉ែត្រ និងបាតស្រះគួរជាដីឥដ្ឋឬខ្សាច់ មានភក់ទាបជាង ២០សង់ទីម៉ែត្រ។ កម្រិត pH ទឹកចន្លោះពី ៧.៥-៨.២ កម្រិតប្រៃចន្លោះពី ១០-២៥‰ សីតុណ្ហភាពចន្លោះពី ២៥-៣៥អង្សាសេ។ ត្រូវជីកប្រឡាយជុំវិញស្រះជម្រៅ ០.៥-០.៧ម៉ែត្រ ទទឹង ១-២ម៉ែត្រ ឬបង្កើតតំបន់ទឹកជ្រៅទំហំពី ១០-១០០ម៉ែ$^{២}$ អាស្រ័យលើទំហំស្រះចិញ្ចឹម ដើម្បីឱ្យក្តាមអាចផ្លាស់ទីរកតំបន់ទឹកដែលមានលក្ខខណ្ឌសមស្រប។ ស្រះចិញ្ចឹមត្រូវបាចកំបោរកសិកម្ម ៥០គីឡូក្រាម/១០០០ម៉ែ$^{២}$ ហើយហាលស្រះរយៈពេលពី ៧-១០ថ្ងៃ។ ស្រះត្រូវហ៊ុមស្បៃឬព្រួលឬស្សីកម្ពស់ ១ម៉ែត្រព័ទ្ធជុំវិញស្រះ ដើម្បីការពារក្តាមវារចេញពីស្រះ។ បន្ទាប់មកត្រូវបញ្ចូលទឹកក្នុងស្រះជម្រៅ ១ម៉ែត្រ និងបង្កើតចំណីធម្មជាតិដោយប្រើជីអ៊ុយរ៉េ ២ គីឡូក្រាម/១០០០ម៉ែ$^{២}$ និងជីដេអាប៉េ ១គីឡូក្រាម/១០០០ម៉ែ$^{២}$។




**៣.២. ការដាក់កូនក្តាមថ្មពូជ÷**

ដើម្បីជៀសវាងហានិភ័យក្នុងអំឡុងពេលចិញ្ចឹម កសិករត្រូវយកចិត្តទុកដាក់ជ្រើសរើសកូនក្តាមដែលមានសុខភាពល្អ ពណ៌សម្បុរភ្លឺថ្លា រត់លឿនខ្លាំង រហ័សរហួន មិនបាក់ជើង មានទំហំប្រហាក់ប្រហែលគ្នាដើម្បីភាពងាយស្រួលក្នុងការថែទាំ។ ប្រសិនបើកសិករជ្រើសរើសកូនក្តាមពូជចេញពីកសិដ្ឋានបង្កាត់ភ្ញាស់ ក្តាមត្រូវមានទំហំចន្លោះពី២-៥សង់ទីម៉ែត្រ ចំណែកកូនក្តាមពីធម្មជាតិគួរជ្រើសរើសទម្ងន់ចន្លោះពី១០-១០០ក្រាម ហើយដង់ស៊ីតេដាក់ចិញ្ចឹមចន្លោះពី ១-៣ក្បាល/ម៉ែ$^{២}$ ។

គួរលែងកូនក្តាមរាយពេញផ្ទៃស្រះ ដោយដាក់កូនក្តាមនៅមាត់ស្រះឱ្យក្តាមវារចូលស្រះដោយខ្លួនឯងនៅពេលចន្លោះម៉ោង៧-៩ព្រឹកដែលមានសីតុណ្ហភាពទាប។មុនពេលលែងកូនក្តាមត្រូវយកចិត្តទុកដាក់លើកម្រិតប្រៃនៃទឹកក្នុងស្រះ មិនត្រូវឱ្យមានភាពប្រែប្រួលខ្លាំងពីទឹកនៅក្នុងធម្មជាតិដែលក្តាមរស់នោះទេ។



**៣.៣. ចំណី និងការផ្តល់ចំណី÷**

ការចិញ្ចឹមក្តាមថ្មក្នុងស្រះ ពឹងផ្អែកច្រើនលើប្រភពចំណីធម្មជាតិដែលមានស្រាប់នៅក្នុងស្រះ នៅពេលសង្កេតឃើញថាចំណីធម្មជាតិកាន់តែចុះទាប ទើបកសិករចាប់ផ្តើមដាក់ចំណីផ្សំដោយខ្លួនឯងបន្ថែម។ ចំណីដែលល្អបំផុតសម្រាប់ក្តាមគឺជាចំណីស្រស់ឬចំណីក្រៀមមានដូចជា÷ កូនត្រីចម្រុះ ខ្យង កូនបង្គារ... បើសិនជាក្រៀមត្រូវត្រាំទឹកធ្វើឱ្យចំណីទន់ជាមុនសិន។ បរិមាណចំណីប្រចាំថ្ងៃចន្លោះពី ៤-៦%នៃទម្ងន់កូនក្តាមសរុបក្នុងស្រះ។ ការផ្តល់ចំណីត្រូវដាក់ពី ២-៤ដង/ថ្ងៃ អាស្រ័យលើដំណាក់កាលលូតលាស់។ពេលកូនក្តាមនៅតូចត្រូវដាក់៣-៤ដង/ថ្ងៃ ក្តាមកាន់តែធំអាចដាក់២ដង/ថ្ងៃ។ ដោយសារក្តាមចាប់ចំណីខ្លាំងនៅ



ពេលយប់ កសិករត្រូវផ្តល់ចំណី១ដងនៅចន្លោះម៉ោង ៥-៧យប់ ដោយបាចចំណីនៅជុំវិញស្រះដើម្បីកាត់បន្ថយការដណ្តើមចំណីគ្នា និងដាក់ចំណីក្នុងកញ្ច្រែងចម្ងាយ ១០ម៉ែត្រពីគ្នា ដើម្បីពិនិត្យលើការស៊ីចំណី។ ក្រោយពេល ពី២-៣ម៉ោង បើពិនិត្យឃើញក្តាមស៊ីចំណីអស់ កសិករត្រូវបន្ថែមចំណី ប៉ុន្តែបើសិនជាឃើញចំណីនៅសល់ កសិករត្រូវបន្ថយចំណីនៅថ្ងៃបន្ទាប់។

## ៣.៤. ការគ្រប់គ្រង និងថែទាំ៖

➢ ដើម្បីធានានូវគុណភាពទឹកក្នុងស្រះបានល្អ ជួយជំរុញឱ្យក្តាមមានសកម្មភាពឬធ្វើបម្លាស់ទីច្រើន ស៊ីចំណីខ្លាំង សកបានល្អ និងលូតលាស់លឿន ស្រះគួរមានប្រព័ន្ធបញ្ចេញបញ្ចូលទឹកស្របជាមួយរបបទឹកជោរ នាចនៃទឹកសមុទ្រដែលអាចផ្លាស់ប្តូរទឹកស្រះបានជាប្រចាំ។ ស្រះដែលមិនមានប្រព័ន្ធបញ្ចេញបញ្ចូលទឹក កសិករត្រូវប្ដូរផ្លាស់ប្តូរទឹក ១-២ដង/ខែ ក្នុងបរិមាណទឹកពី ២០-៣០% ជាពិសេសនៅចុងនៃវគ្គចិញ្ចឹមទម្ងន់ក្តាមបានកើនឡើង និងស៊ីចំណីច្រើននាំឱ្យទឹកងាយខូចគុណភាព ដូចនេះត្រូវត្រួតពិនិត្យ និងផ្លាស់ប្តូរទឹកស្រះឱ្យបានទៀងទាត់។

***តារាងប៉ារ៉ាម៉ែត្រនៃគុណភាពទឹក៖***

| ល.រ | ប៉ារ៉ាម៉ែត្រនៃគុណភាពទឹក | កម្រិតសមស្រប |
|---|---|---|
| ១ | pH | ៧.៥-៨.៥ |
| ២ | អុកស៊ីសែនរលាយក្នុងទឹក (DO) | >៣ មីលីក្រាម/លីត្រទឹក |
| ៣ | កំហាប់អំបិល/កម្រិតប្រៃ | ១៥-២៥ ភាគពាន់ |
| ៤ | សីតុណ្ហភាពទឹក | ២៦-៣០ អង្សាសេ |

➢ ចាប់កូនក្តាមធ្វើសំណាក១-២ដង/ខែ ដើម្បីកំណត់ទម្ងន់ក្តាមជាមធ្យមក្នុង១ក្បាល ទម្ងន់ក្តាមសរុបក្នុងស្រះ វាយតម្លៃការលូតលាស់ កំណត់បរិមាណចំណីត្រូវផ្តល់ ពិនិត្យរូបរាង សុខភាព កំណត់បាននូវបញ្ហា និងអាចដោះស្រាយបានទាន់ពេលវេលា។

➢ ឧស្សាហ៍ពិនិត្យ ថែទាំភ្លឺស្រះ របាំងការពារជុំវិញស្រះ និងប្រព័ន្ធបញ្ចេញបញ្ចូលទឹក។




## ៣.៥. ការបង្ការជំងឺ ៖

នៅក្នុងវារីវប្បកម្ម ក្តាមថ្មត្រូវបានចាត់ទុកថាជាសត្វដែលកើតជំងឺតិចតួចបំផុត បើធៀបនឹងបង្គា ត្រី និងប្រភេទសត្វសមុទ្រផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏អាចមានករណីមួយចំនួនដែលបណ្តាលឱ្យក្តាមឈឺ ហើយជំងឺទាំងនេះក៏ស្រដៀងទៅនឹងជំងឺនៅលើសត្វបង្គា និងបង្កងផងដែរ។ ក្នុងធម្មជាតិ ករណីក្តាមកើតមានជំងឺគឺមានកម្រិតទាប ប៉ុន្តែនៅពេលកសិករចាប់ផ្តើមអនុវត្តការចិញ្ចឹមតាមបែបប្រពលវប្បកម្ម ឬ

ការតម្លើងដង់ស៊ីតេនៃកូនក្តាមខ្ពស់ពេក នាំឱ្យអត្រាកើតឡើងនៃជំងឺកាន់តែខ្ពស់ ដូចនេះកសិករត្រូវសិក្សាស្វែងយល់អំពីវិធីបង្ការជំងឺមួយចំនួនដូចខាងក្រោម÷

- ស្រះត្រូវរៀបចំឱ្យបានត្រឹមត្រូវមុនពេលដាក់ចិញ្ចឹម÷ ត្រូវសម្អាតកាកសំណល់ចេញពីស្រះ បូមឬបាភក់បាតស្រះឱ្យនៅត្រឹមកម្រិតទាបបំផុត និងហាលស្រះទុករយៈពេលពី ៥-១០ថ្ងៃ។
- បាចកំបោរកសិកម្មសម្លាប់មេរោគជុំវិញស្រះ និងក្នុងស្រះក្នុងកម្រិត ៥គីឡូក្រាម/១០០ម៉$^{២}$
- ដាក់កូនក្តាមចិញ្ចឹមក្នុងកម្រិតសមស្របតាមបច្ចេកទេស ផ្តល់ចំណីឱ្យបានគ្រប់គ្រាន់
- គ្រប់គ្រងគុណភាពទឹកឱ្យបានសមស្រប ជាពិសេសកម្រិត pH និងកម្រិតប្រៃនៃទឹក
- កូនក្តាមពូជដាក់ចិញ្ចឹមមានសុខភាពល្អ គ្មានជំងឺ និងមានទំហំចាប់ពី ១.៥សង់ទីម៉ែត្រឡើង
- មុនពេលលែងចូលស្រះកូនក្តាមត្រូវសម្លាប់មេរោគ ដោយ Formalin ២០-៣០ ppm ឬប្រើស្ពាន់ធ័រស្ប៉ូង Copper Sulfate ២-៤ ppm ត្រាំកូនក្តាមពី ២០-៣០នាទី។
- ចំណីដាក់ឱ្យក្តាមស៊ីជាប្រភេទចំណីស្រស់មិនខូចគុណភាព



### ៣.៦. ការប្រមូលផល÷

បន្ទាប់ពីចិញ្ចឹមបានរយៈពេលពី ៤-៦ខែ ក្តាមថ្មមានទម្ងន់ចន្លោះពី0.១-0.៣គ.ក/ក្បាល ឬចំនួនកូនក្តាមថ្មពី ៣-១០ក្បាល/គ.ក កសិករអាចចាប់ផ្តើមប្រមូលផលរំលស់ ដោយចាប់ក្តាមដែលមានទំហំធំត្រូវនឹងតម្រូវការទីផ្សារ ហើយរក្សាទុកកូនក្តាមមានទំហំតូចចិញ្ចឹមបន្ត។ ការប្រមូលផលរំលស់កសិករប្រើឧបករណ៍លបកន្ទុយកណ្តុរ ឬលបប្រឹស១០០ ដែលមិនប៉ះពាល់ដល់គុណភាពក្តាម។ ការប្រមូលផលសម្រេចធ្វើឡើងក្រោយពេលចិញ្ចឹមបាន ១០ខែ ឬនៅពេលកូនក្តាមនៅសល់ត្រឹម១០-២០% ដោយការបូមទឹកពង្រីង និងចាប់យកកូនក្តាមទាំងអស់តែម្តង។ កសិករមួយចំនួនបានដាក់កូនក្តាមពូជចិញ្ចឹមនៅវគ្គបន្តតែម្តងដោយមិនបានសម្អាតស្រះឡើងវិញនោះទេ បើសិនជាពិនិត្យឃើញគុណភាពទឹកនៅល្អ និងល្បាប់ភក់មានតិចតួច។



## ៤-គម្រោងអាជីវកម្មចិញ្ចឹមក្ដាមថ្ម ÷

### ៤-១-គម្រោងចិញ្ចឹម (បទពិសោធន៍របស់កសិករចិញ្ចឹមក្ដាមថ្ម នៅខេត្តកំពត)

- ទំហំស្រះចិញ្ចឹម ÷ ១០,០០០ម៉$^2$ (១ហិកតា)
- ចំនួនកូនក្ដាមពូជ/វគ្គ ÷ ១០,០០០ក្បាល
- រយៈពេលចិញ្ចឹម ÷ ១០ខែ/វគ្គ
- ចំណី ÷ បន្ថែមចំណីត្រីនុយ និងចំណីធម្មជាតិនៅក្នុងស្រះ
- អត្រាបាត់បង់ ÷ មធ្យម ៤០% (អាស្រ័យលើទំហំ សុខភាពកូនពូជ និងការថែទាំ)
- ទិន្នផល ÷ មធ្យម ១,៥០០គ.ក/វគ្គ ( ជាមធ្យម ០.២៥គ.ក/ក្បាល)
- ទីផ្សារ ÷ ឈ្មួញក្នុងតំបន់បញ្ជាទិញពីកសិដ្ឋានផ្ទាល់
- តម្លៃទីផ្សារ ÷ លក់បោះដុំតម្លៃជាមធ្យម ៥០,០០០រៀល/គ.ក
- តម្រូវការទុនសម្រាប់ការចាប់ផ្ដើមអាជីវកម្មដំបូង ដោយរៀបចំស្រះ និងបំពាក់សម្ភារៈ ÷

| ទុនវិនិយោគសម្រាប់ជីកស្រះ និងបំពាក់សម្ភារៈ (រៀល) | ទុនសម្រាប់ដំណើរការចិញ្ចឹម (រៀល) | ទឹកប្រាក់សរុបសម្រាប់ចាប់ផ្ដើមអាជីវកម្មដំបូង (រៀល) |
|---|---|---|
| **6,960,000** | **15,640,000** | **22,600,000** |

### ៤-២-ការវិភាគសេដ្ឋកិច្ចការចិញ្ចឹមក្ដាមថ្មក្នុង១វគ្គ (រយៈពេល ១០ខែ)÷

ការចិញ្ចឹមក្ដាមថ្ម ដោយដាក់កូនពូជចំនួន **១០,០០០ក្បាល** ចិញ្ចឹមរយៈពេល ១០ខែ (ក្នុង១វគ្គ) មានអត្រាបាត់បង់ជាមធ្យម ៤០% និងក្រោយកាត់រំលស់ឧបករណ៍ សម្ភារៈ រួមមានដូចខាងក្រោម÷

| លរ | មុខចំណាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ/ឯកត្តា (៛) | តម្លៃសរុប (៛) | ចំនួនវគ្គរំលស់ | តម្លៃសរុប/វគ្គ (៛) |
|---|---|---|---|---|---|---|---|
| **I-ចំណូលពីការលក់ក្ដាមសាច់** | | | | | | | |
| 1 | ចំណូលពីការលក់ | គ.ក | 1,500 | 50,000 | 75,000,000 | | **75,000,000** |
| **II-ចំណាយសរុប (ក + ខ)** | | | | | **22,600,000** | | **16,624,000** |
| **ក-ការចំណាយប្រែប្រួល** | | | | | **15,640,000** | | **15,640,000** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 1 | កូនក្តាមពូជ | ក្បាល | 10,000 | 1,000 | 10,000,000 | | 10,000,000 |
| 2 | កំបោរស | គ.ក | 1000 | 2,000 | 2,000,000 | | 2,000,000 |
| 3 | ចំណី(ប្រភេទត្រីនុយ) | គ.ក | 240 | 1,000 | 240,000 | | 240,000 |
| 4 | ប្រេងសាំងឬម៉ាស៊ូត/វគ្គ | ខែ | 4 | 400,000 | 1,600,000 | | 1,600,000 |
| 5 | ថ្នាំការពារ និងព្យាបាល (១វគ្គ) | វគ្គ | 1 | 200,000 | 200,000 | | 200,000 |
| 6 | កម្លាំងពលកម្ម/វគ្គ(២០%) | ខែ | 4 | 400,000 | 1,600,000 | | 1,600,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | **6,960,000** | | **984,000** |
| 1 | ជីកស្រះ | ហិកតា | 1 | 1,800,000 | 1,800,000 | 20 | 90,000 |
| 2 | ម៉ាស៊ីនបូមទឹក | គ្រឿង | 1 | 1,200,000 | 1,200,000 | 10 | 120,000 |
| 3 | ក្បាលម៉ាស៊ីនកិនចំណី | គ្រឿង | 1 | 1,200,000 | 1,200,000 | 10 | 120,000 |
| 4 | ទុយោបូមទឹក ទន់ (៥០ម/ ដុំ) | ដុំ | 4 | 60,000 | 240,000 | 10 | 24,000 |
| 5 | ស្បៃហ៊ុំស្រះ | គ.ក | 100 | 10,000 | 1,000,000 | 4 | 250,000 |
| 6 | បង្គោលឈើ | ដើម | 200 | 2,000 | 400,000 | 4 | 100,000 |
| 7 | លបមុខ១០០ | វង់ | 20 | 20,000 | 400,000 | 4 | 100,000 |
| 8 | ជញ្ជីងថ្លឹង(អេឡិចត្រូនិច-ប៉ុង) | គ្រឿង | 2 | 260,000 | 520,000 | 4 | 130,000 |
| 9 | តាកា ចានដែក ធុង... | ឈុត | 1 | 200,000 | 200,000 | 4 | 50,000 |
| III-**ចំណេញសរុប** | | | | | | | **58,376,000** |
| **ចំណាយថ្លៃដើមក្នុងការចិញ្ចឹមក្តាមថ្មក្នុង១ គ.ក** | | | | | | | **11,083** |
| ចំណេញពីការផលិតក្តាមថ្មសាច់ ១ គ.ក | | | | | | | **38,917** |

## ៤-៣-ការវិភាគលទ្ធផលដោយផ្អែកលើនិន្នាកាតម្លៃលក់ ÷

តាមរយៈបទពិសោធន៍របស់កសិករដែលក្រុមការងារបានសិក្សាផ្ទាល់ ការចិញ្ចឹមក្តាមថ្មនៅក្នុងស្រះមានអត្រាបាត់បង់ចន្លោះពី ៣០-៥០% អាស្រ័យលើសុខភាពកូនក្តាមពូជ ការគ្រប់គ្រង និងការថែទាំ។

| ទិន្នផល (គ.ក) | តម្លៃលក់ (រៀល) | ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | ចំណេញ (រៀល) | កំណត់សម្គាល់អំពីទិន្នផល |
|---|---|---|---|---|---|
| 1,250 | 60,000 | 75,000,000 | 16,624,000 | 58,376,000 | ករណីអត្រាបាត់បង់៥០% |
| | 50,000 | 62,500,000 | 16,624,000 | 45,876,000 | |
| | 45,000 | 56,250,000 | 16,624,000 | 39,626,000 | |
| 1,500 | 60,000 | 90,000,000 | 16,624,000 | 73,376,000 | ករណីអត្រាបាត់បង់៤០% |
| | 50,000 | 75,000,000 | 16,624,000 | 58,376,000 | |
| | 45,000 | 67,500,000 | 16,624,000 | 50,876,000 | |
| 1,750 | 60,000 | 105,000,000 | 16,624,000 | 88,376,000 | ករណីអត្រាបាត់បង់៣០% |
| | 50,000 | 87,500,000 | 16,624,000 | 70,876,000 | |
| | 45,000 | 78,750,000 | 16,624,000 | 62,126,000 | |

**សម្គាល់÷**

ក្នុងករណីកូនក្តាមថ្មពូជដែលទិញបានពីធម្មជាតិមានសុខភាពមិនល្អ ការគ្រប់គ្រង និងថែទាំមិនបានត្រឹមត្រូវ ធ្វើឱ្យប៉ះពាល់ដល់សុខភាពកូនក្តាមនាំឱ្យអត្រាបាត់បង់ខ្ពស់ និងផលចំណេញធ្លាក់ចុះ។ ដោយឡែកតម្លៃក្តាមថ្មសាច់នៅលើទីផ្សារមានការប្រែប្រួលតិចតួច ក្នុងនោះប្រភេទក្តាមថ្មសាច់លេខ១ ដែលមានទម្ងន់ ៣-៤ក្បាល/គ.ក លក់បានតម្លៃចន្លោះពី៥៥,០០០-៦០,០០០៛/គ.ក និងប្រភេទលេខ០២ មានក្តាម ៥ក្បាល/គ.ក លក់បានតម្លៃពី ៤៥,០០០-៥០,០០០៛/គ.ក។

## ៤-៤-ការវិភាគលើខ្សែច្រវាក់តម្លៃ÷

| តម្លៃក្តាមថ្មសាច់ខាងក្រោម គឺវិភាគលើតម្លៃរួមជាមធ្យមទាំងក្តាមប្រភេទលេខ១ និងលេខ២។ | |
|---|---|
| | **កសិករ** ÷ ករណីលក់ទៅឈ្មួញកណ្តាលបោះដុំក្នុងតម្លៃមធ្យម ៥០,០០០៛/គ.ក តម្លៃថ្លៃដើមផលិត ១១,០៨០៛/គ.ក កសិករអាចចំណេញបាន ៣៨,៩១៧៛/គ.ក ។ |
| | **ឈ្មួញកណ្តាល**÷ លក់ទៅអ្នកលក់រាយក្នុងផ្សារបានតម្លៃ ៦០,០០០៛/គ.ក កាត់លើថ្លៃដឹកជញ្ជូន លើកដាក់ ១,០០០៛/គ.ក អាចចំណេញបាន ៩,០០០៛/គ.ក ។ |
| | **អ្នកលក់រាយ** ÷ លក់បានតម្លៃ ៨០,០០០៛/គ.ក កាត់លើថ្លៃដឹកជញ្ជូន លើកដាក់ និងថែរក្សា ១,៥០០៛/គ.ក អាចចំណេញបាន ១៨,៥០០៛/គ.ក ។ |

## ៥-ហានិភ័យ និងបញ្ហាប្រឈម

តាមការសិក្សាផ្ទាល់ជាមួយកសិករចិញ្ចឹមក្តាមថ្មនៅខេត្តកំពត កសិករដែលមានបំណងប្រកបរបរចិញ្ចឹមក្តាមថ្មត្រូវស្វែងយល់វិធីគ្រប់គ្រងហានិភ័យ និងបញ្ហាប្រឈមចម្បងៗមួយចំនួនទៅលើអាជីវកម្មរួមមានដូចខាងក្រោម÷

| ល.រ | ប្រភេទហានិភ័យ | ការពិពណ៌នាហានិភ័យ | វិធានការក្នុងការគ្រប់គ្រងហានិភ័យ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | ទីតាំងចិញ្ចឹមមានរបបទឹកជោរនាច ធ្វើឱ្យងាយរងនូវការបំពុល កំហាប់អំបិលប្រែប្រួលលឿន អាចប៉ះពាល់ដល់ការលូតលាស់របស់ក្តាម។ | - ស្វែងយល់ពីប្រវត្តិតំបន់ និងទីតាំងភូមិសាស្ត្រឱ្យបានច្បាស់លាស់។<br>- មុនពេលបញ្ចេញ-បញ្ចូលទឹកត្រូវស្វែងយល់ពីស្ថានភាពបរិស្ថាន ស្ថានភាពជោរ-នាចនៃទឹកសមុទ្រ និងពិនិត្យគុណភាពទឹកជាមុន។ |

| | | | |
|---|---|---|---|
| | | កូនក្ដាមពូជមិនល្អ មានផ្ទុកជំងឺ សុខភាពខ្សោយ នាំឱ្យការលូតលាស់យឺត និងមានអត្រាបាត់បង់ខ្ពស់ ។ | - ស្វែងយល់ពីប្រវត្តិកសិដ្ឋានផលិតកូនក្ដាមពូជ<br>- ណែនាំអ្នកនេសាទក្ដាមធម្មជាតិអំពីការនេសាទដែលសមស្រប ការរក្សាទុក និងការដឹកជញ្ជូនកូនក្ដាមឱ្យមានសុវត្ថិភាព។<br>- កូនក្ដាមត្រូវសម្លាប់មេរោគមុនពេលដាក់ចិញ្ចឹម |
| | | ការគ្រប់គ្រង និងថែទាំមិនបានដិតដល់ នឹងបង្ករឱ្យក្ដាមមានសុខភាពមិនល្អ កើតជំងឺ ប៉ះពាល់ដល់ការលូតលាស់ និងមានការបាត់បង់ខ្ពស់។ | - ត្រួតពិនិត្យគុណភាពទឹក និងមានការផ្លាស់ប្ដូរទឹកពី ២០-៣០%ជាប្រចាំ។<br>- ផ្ដល់ចំណីគ្រប់គ្រាន់តាមបច្ចេកទេស មិនលើស មិនខ្វះ។<br>- មានកម្មវិធីបង្ការជំងឺ រក្សាលំនឹងសារធាតុចិញ្ចឹម កម្ចាត់បាក់តេរី និងប៉ារ៉ាស៊ីត។<br>- តាមដានការលូតលាស់របស់ក្ដាមជាប្រចាំ |
| ២ | **ហានិភ័យហិរញ្ញវត្ថុ** | ការចិញ្ចឹមទ្រង់ទ្រាយធំ អាជីវករត្រូវមានទុនបម្រុងទុក សម្រាប់ទិញចំណី និងវត្ថុធាតុដើមក្នុងការផលិតចំណី ដែលមានការចំណាយខ្ពស់។ | - ទោះជាការចិញ្ចឹមទ្រង់ទ្រាយតូចឬធំ ផែនការអាជីវកម្មត្រូវមានជាចាំបាច់។<br>- កសិករអាចអាចប្រមូលផលបណ្ដាក់ដោយចាប់ក្ដាមដែលមានទំហំស្របតាមតម្រូវការទីផ្សារធ្វើជាទុនចិញ្ចឹមបន្ត។ |

## ៦-សេចក្ដីសន្និដ្ឋាន

ការចិញ្ចឹមក្ដាមថ្ម មិនសូវមានការលំបាកនោះទេ ប៉ុន្តែអ្នកចិញ្ចឹមត្រូវធ្វើការសិក្សាស្វែងយល់អំពីបច្ចេកទេសឱ្យបានច្បាស់លាស់មុនពេលចាប់ផ្ដើមអាជីវកម្ម។ ត្រូវមានទីតាំងចិញ្ចឹមក្ដាមសមស្រប ប្រភពកូនក្ដាមពូជល្អ ការថែទាំ និងការគ្រប់គ្រងលើដំណើរការចិញ្ចឹមគឺជាកត្តាចម្បងដែលអ្នកចិញ្ចឹមត្រូវយកចិត្តទុកដាក់ខ្ពស់។ ថ្លៃដើមផលិតក្ដាមថ្មជាមធ្យម ១១,០៨៣រៀល/គ.ក បើលក់បានតម្លៃជាមធ្យម ៥០,០០០ រៀល/គ.ក កសិករអាចទទួលបានចំណេញខ្ពស់រហូតដល់ ៣៨,៩១៧រៀល/គ.ក។ ការចិញ្ចឹមក្ដាមថ្ម កសិករត្រូវយកចិត្តទុកដាក់លើចំណុចចម្បងសំខាន់ៗមួយចំនួនមានដូចជា÷ ជ្រើសរើសទីតាំងឱ្យបានសមស្របពីព្រោះស្រះចិញ្ចឹមត្រូវការផ្លាស់ប្ដូរទឹកជាប្រចាំ កូនក្ដាមពូជត្រូវមានគុណភាពល្អ ថែទាំ-គ្រប់គ្រងស្រះចិញ្ចឹមឱ្យបានត្រឹមត្រូវ ដើម្បីកាត់បន្ថយហានិភ័យ និងអត្រាបាត់បង់។

**ប្រភព និងឯកសារសម្រាប់សិក្សាស្រាវជ្រាវ÷**

១- កសិករចិញ្ចឹមក្ដាមថ្ម នៅខេត្តកំពត

២- បច្ចេកទេសចិញ្ចឹមក្ដាមថ្ម តាមគេហទំព័រមួយចំនួនទាំងក្នុង និងក្រៅស្រុក÷

- *https://farmerdna.com/tips-in-starting-sucessful-mud-crab-farming/*
- *https://www.facebook.com/watch/?v=906564893209496*
- *https://www.youtube.com/watch?v=pI1JXrLpXKs*
- *https://www.youtube.com/watch?v=uV9VvWQV3eI*
- *https://aquaculture.vn/khoa-hoc-ky-thuat/cua-bien-mot-so-benh-thuong-gap-va-bien-phap-phong-tri*
- *https://tepbac.com/technical/full/358-ky-thuat-nuoi-cua-thuong-pham-tu-giong-nhan-tao-trong-ao-dat-phan-2.htm*
- *https://thuysanvietnam.com.vn/phong-tri-benh-tren-cua-bien/*